ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៩០៥ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបែងចែកភារកិច្ចជូនអនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ទទួលជួយលើការងារប្រឆាំងផលិតផលក្លែងក្លាយ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ៥៧២០ សសរ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីណែនាំលេខ ០១២ សណន ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអគ្គនាយក ឬប្រធានអង្គភាពប្រហាក់ប្រហែល ចំណុះក្រសួងមហាផ្ទៃ
- បានឃើញសេចក្តីសម្រេចលេខ ៣៤៥៤ សសរ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីការកែសម្រួល និងប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

## សម្រេច

**ប្រការ១** ..

ត្រូវបានបែងចែកភារកិច្ចជូន ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលជួយ ឯកឧត្តម **មៀច សុផាន់ណា** រដ្ឋលេខាធិការ លើការងារប្រឆាំងផលិតផលក្លែងក្លាយ ដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម **ភឹម ជាតិ** អនុរដ្ឋលេខាធិការ ទទួលជួយទំនាក់ទំនងជាមួយក្រសួងសុខាភិបាល លើការងារត្រួតពិនិត្យផលិតផលថ្នាំជក់ ការងារលុបបំបាត់ឱសថក្លែងក្លាយ និងសេវាសុខាភិបាលខុសច្បាប់ ដើម្បីកាត់បន្ថយភាពក្រីក្រ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការងារស្តង់ដារជាតិ។

២-ឯកឧត្តម **សរ សិទ្ធិ** អនុរដ្ឋលេខាធិការ ទទួលជួយទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងការងារសុវត្ថិភាពម្ហូបអាហារ។

៣-ឯកឧត្តម **សុខ សារេត** អនុរដ្ឋលេខាធិការ ទទួលជួយទំនាក់ទំនងជាមួយក្រសួងពាណិជ្ជកម្ម លើការងារកម្មសិទ្ធិបញ្ញា និងការងារការពារអ្នកប្រើប្រាស់។

**ប្រការ២** .-

ឯកឧត្តម អនុរដ្ឋលេខាធិការ ដូចមានចែងក្នុងប្រការ១ ត្រូវបំពេញការងារផ្សេងៗទៀតតាមការចាត់ចែង របស់ឯកឧត្តម រដ្ឋលេខាធិការ ទទួលជួយរដ្ឋមន្ត្រីលើការងារប្រឆាំងផលិតផលក្លែងក្លាយ។

**ប្រការ៣** .-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ថ្ងៃ ច័ន្ទ ១២រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

*កន្លែងទទួល ៖*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
*-ដូចប្រការ៣*
*-ឯកសារ-កាលប្បវត្តិ*